# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តកំពង់ធំ

<u>សាលក្រម</u>

លេខ ៣៤ ក ចុះថ្ងៃទី ២៨

ខែ កក្កដា ឆ្នាំ ២០០៥

<u>សំណុំរឿង</u>

លេខ ៦៧ ចុះថ្ងៃទី ០៩

ខែ ឧសភា ឆ្នាំ ២០០៥

**គាននាមប្រជារាស្ត្រខ្មែរ**

តុលាការខេត្តកំពង់ធំ បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តកំពង់ធំ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ ដោយមានសមាសភាពដូចតទៅ:

**<u>ចៅក្រមជំនុំជំរះ</u>**

លោក[redacted]

**<u>តំណាងអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

*សាលក្រមនេះចូលស្ថាពរចាប់តាំងពីថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥ តទៅ*
*ដោយគូក្តីមិនចូលតវ៉ាតាមកំណត់ច្បាប់ ។*
*កំពង់ធំ,ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥*
***ប្រធានតុលាការខេត្ត***
[redacted]

ដើម្បីជំនុំជំរះរឿងក្តីរដ្ឋប្បវេណីលេខ ៦៧ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ដែលមានកម្មវត្ថុបណ្តឹង **ប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្តី ។**

-រវាងដើមចោទ **ត ចណ** ភេទស្រី អាយុ ៣០ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ របររកស៊ីលក់ដូរ ទីលំនៅសព្វថ្ងៃភូមិកំពង់ធំ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ប្តីឈ្មោះ **ឲ បហ** មានកូន ០១នាក់ ឪពុកឈ្មោះ **ត ឃ** (ស) ម្តាយឈ្មោះ **ឲ ឈ** (រ) ។

-និង ចុងចម្លើយឈ្មោះ **ឲ បហ** ហៅ **ខ** ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ សព្វថ្ងៃនៅភូមិសានគរ ឃុំសានគរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ របររកស៊ីគ្រូបង្រៀន ប្រពន្ធឈ្មោះ **ត ចណ** មានកូន ០១នាក់ ឪពុកឈ្មោះ **ឲ ធគ** (ស) ម្តាយឈ្មោះ **ច សរ** (រ) ។

**<u>ងរឿងហេតុមានដូចតទៅ</u>**

តាមពាក្យបណ្តឹងចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៥ របស់ដើមចោទឈ្មោះ **ត ចណ** បានប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្តីឈ្មោះ **ឲ បហ** ដោយសំអាងហេតុថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ **ឲ បហ** ត្រឹមត្រូវតាមច្បាប់តាំងពីឆ្នាំ ១៩៩៦ ការរស់នៅជាមួយគ្នាបានកូនប្រុសម្នាក់ លុះក្រោយមកប្តីត្រូវបានទទួលអសមត្ថភាពនៃលិង្គ ខ្លួនមិនអាចទ្រាំរស់នៅជាប្តីប្រពន្ធបានទេ ។

-បានឃើញរបាយការណ៍ជូនរឿងទៅជំនុំជំរះលេខ ៣៧៧ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៥ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ៣៧៨ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៥ ។

## នរពេលសទនាគារ

-ដើមចោទឈ្មោះ ត ចណ បានឆ្លើយបញ្ជាក់ថា ខ្លួនរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ ឋ បឃ ត្រឹមត្រូវតាមប្រពៃណីតាំងពីឆ្នាំ ១៩៩៦ មករួមរស់នៅជាមួយគ្នារយៈពេល ០៣ឆ្នាំទើបបានកូនប្រុសម្នាក់ឈ្មោះ ឋ ឌ អាយុ ០៦ឆ្នាំ រហូតដល់ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៥ ខ្លួនក៏បែកលំនៅសង្វាសពីគ្នាដោយមូលហេតុកន្លងមកការរួមរស់ជាមួយប្តីតាំងពីថ្ងៃផ្សំដំណេករហូតរយៈពេល០៣ឆ្នាំ ប្តីបានដេករួមរ័ក្សជាមួយខ្លួនបានយ៉ាងច្រើនត្រឹម ១០ដង ហើយបន្ទាប់មកខ្លួនមានផ្ទៃពោះ ០១ខែរហូតដល់កូនអាយុ ០៦ឆ្នាំ ប្តីមិនដែលបានដេករួមរ័ក្សជាមួយខ្លួន ជាហេតុធ្វើឱ្យខ្លួនអស់មនោសញ្ចេតនានឹងគ្នា ។ ទ្រព្យសម្បត្តិដើមខ្លួន និង ទ្រព្យសម្បត្តិរួមគ្មានទេ ។ ខ្លួនសំណូមពរសុំឱ្យបានលែងលះពីប្តី និង សុំគ្រប់គ្រងកូនប្រុសម្នាក់ មិនទាមទារអាហារកិច្ចចិញ្ចឹមកូនទេ ។

-ចុងចម្លើយឈ្មោះ ឋ បឃ បានឆ្លើយបញ្ជាក់ថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ ត ចណ ត្រឹមត្រូវតាមប្រពៃណីតាំងពីឆ្នាំ ១៩៩៦ មកដូចចម្លើយដើមចោទ ការរួមរស់នៅជាមួយគ្នាកន្លងមកបានកូនប្រុសម្នាក់ឈ្មោះ ឋ ឌ អាយុ ០៦ឆ្នាំ ឯការរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធចាប់ពីប្រពន្ធមានផ្ទៃពោះរហូតកូនអាយុ ០៦ឆ្នាំ ខ្លួនមិនបានដេករួមរ័ក្ស និង ប្រពន្ធទេដោយអសមត្ថភាពនៃលឹង្គ ហើយក៏បែកលំនៅសង្វាសពីគ្នាទៅនៅផ្ទះម្តាយឯសានគររហូតដល់សព្វថ្ងៃ ។ ទ្រព្យសម្បត្តិដើមខ្លួនមានខ្សែក ចិញ្ចៀន ០១វង់មាសសុទ្ធ ០១ដំឡឹង ០៣ជី និង ប្រាក់ ៣០០ដុល្លា នៅលើប្រពន្ធគ្រប់គ្រង ឯទ្រព្យសម្បត្តិរួមគ្មានទេ ។ ចំពោះការលែងលះរបស់ដើមចោទ គឺខ្លួនសុខចិត្តលែងលះដែរ ដោយខ្លួនមានជំងឺប្រចាំកាយ ។

## តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា :

ចំពោះរឿងក្តីនេះអយ្យការស្នើសុំតុលាការសំរេចតាមច្បាប់ ។

-ក្រោយពីបានស្តាប់ដើមចោទឆ្លើយអោយការណ៍ និង ប្តឹងសុំ
-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ចុងចម្លើយ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តកំពង់ធំ

-យល់ឃើញថា : ពាក្យបណ្តឹងចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៥ របស់ដើមចោទឈ្មោះ ត ចណ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-យល់ឃើញថា : ដើមចោទឈ្មោះ ត ចណ បានប្តឹងសុំផ្តាច់សមគ្គសង្វាសពីចុងចម្លើយឈ្មោះ ឋ បឃ ដោយសំអាងហេតុថា ខ្លួនបានរៀបការជាមួយចុងចម្លើយជាប្តីប្រពន្ធនឹងគ្នាតាំងពីឆ្នាំ ១៩៩៦ នៅរួមរស់នៅជាមួយគ្នាមានកូន ០១នាក់ ប្តីក៏អសមត្ថភាពនៃលឹង្គជាហេតុធ្វើអោយខ្លួនមិនអាចនៅរួមរស់ជាមួយគ្នាតទៅទៀតបាន ទើបប្តឹងសុំលែងលះមកតុលាការនេះ ។

-យល់ឃើញថា : មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដើមចោទ និង ចុងចម្លើយពិតជាបានរៀបអាពាហ៍ពិពាហ៍ជាប្តីប្រពន្ធនឹងគ្នាតាមច្បាប់កាលពីឆ្នាំ ១៩៩៦ រួមរស់នៅជាមួយគ្នាបានកូន ០១នាក់ ហើយប្តីអសមត្ថភាព

នៃលិង្គប្រាកដមែន ។

-យល់ឃើញថា : កូនមានម្នាក់ឈ្មោះ ៩ ៖ជ ភេទប្រុស អាយុ ០៦ឆ្នាំ គូភាគីបានឯកភាពប្រគល់ឱ្យដើមចោទ គ្រប់គ្រងថែរក្សាដោយគ្មានទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនទេនោះ មានលក្ខណៈសមស្របតាមច្បាប់ ។

-យល់ឃើញថា ទ្រព្យសម្បត្តិដើមរបស់ចុងចម្លើយមាន : ខ្សែកមាស ០១ខ្សែ ចិញ្ចៀនមាស ០១វង់ ទំងន់ ០១ដំឡឹង ០៣ជី និង ប្រាក់ ៣០០ដុល្លានៅលើដើមចោទគ្រប់គ្រង ។

-យល់ឃើញថា ទ្រព្យសម្បត្តិរួមរបស់គូភាគីគ្មានទេ ។

## ហេតុដូច្នេះតុលាការខេត្តកំពង់ធំ
## វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៥ របស់ដើមចោទឈ្មោះ ត ចណា ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-សំរេចឱ្យដើមចោទឈ្មោះ ត ចណា និង ចុងចម្លើយឈ្មោះ ៩ មហ ដាច់សមគ្គសង្វាសពីគ្នា តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ចាប់ពីសាលក្រមនេះមានអានុភាពអនុវត្តតទៅ ។ ដាក់កំហុសលើចុងចម្លើយ ។

៣-ឱ្យឈ្មោះនាង ត ចណា ស្ថិតនៅក្នុងភាពមេម៉ាយចំនួន ៣០០ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៤-ប្រគល់កូនប្រុសម្នាក់ឈ្មោះ ៩ ៖ជ អាយុ ០៦ឆ្នាំ អោយទៅដើមចោទឈ្មោះ ត ចណា គ្រប់គ្រងចិញ្ចឹមថែរក្សា ។ ទុកសិទ្ធិអោយចុងចម្លើយឈ្មោះ ៩ មរ៉េ ទៅសួរសុខទុក្ខកូនបានតាមមាត្រា ៧៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។

៥-ប្រគល់ទ្រព្យសម្បត្តិដើមរបស់ចុងចម្លើយមាន :ខ្សែក និង ចិញ្ចៀនមាស ០១ដំឡឹង ០៣ជី និង ប្រាក់ ៣០០ដុល្លាឱ្យទៅចុងចម្លើយឈ្មោះ ៩ មហ គ្រប់គ្រង ។

៦-បង្គាប់ឱ្យចុងចម្លើយឈ្មោះ ៩ មហ បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តីពន្ធហ្នឹង ១.៨០០៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛០០ រង្វាន់ប្រគល់ដីកាកោះ ៥.០០០៛០០ សរុប ៧.០០០៛០០ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០៛០០ ដែលដើមចោទបានបង់រួចហើយ ផុតកំណត់ឧទ្ធរណ៍អោយចុងចម្លើយសងទៅដើមចោទវិញ ។

៧-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើភាគីណាមិនសុខចិត្តមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ០២ខែតាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**

**ហត្ថលេខា និង ត្រា**

[redacted]

**បានឃើញ**

**ប្រធានតុលាការខេត្ត**

[redacted]